# វិបត្តិសាកល — ផលប៉ះពាល់ ចក្ខុវិស័យ និងជំរើសគោល នយោបាយសំរាប់កម្ពុជា

*អត្ថបទនេះ ពណ៌នាសង្ខេបនូវចំនុចសំខាន់ៗនៃបទបង្ហាញរបស់លោក John Nelmes ក្នុងវគ្គទី១ នៃសន្និសីទស្តីពីចក្ខុវិស័យកម្ពុជា ឆ្នាំ២០០៩ ។*

## វិបត្តិ: ដើមហេតុ និងផលប៉ះពាល់ជាសាកល

វិបត្តិសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន មានសភាពអាក្រក់ជាងមហាវិបត្តិសេដ្ឋកិច្ចទសវត្សរ៍១៩៣០ ទៅទៀត ។ ចំនុចទីមួយ និងសំខាន់បំផុត គឺផលប៉ះពាល់នៃវិបត្តិ បានរីករាលដាលទៅឆ្ងាយ និងយ៉ាងលឿន ដោយសឹងមិនចន្លោះប្រទេសណាមួយឡើយ ។ វិបត្តិនេះ ផ្តើមចេញពីសហរដ្ឋអាមេរិក និងរាលដាលទៅកាន់ប្រទេសអភិវឌ្ឍន៍ដទៃទៀត ហើយនៅអំឡុងឆ្នាំ២០០៨ វាឡើងដល់កំរិតកំពូលនិងរាលដាលទៅដល់ប្រទេសឯទៀតៗក្នុងពិភពលោក ដោយមានផលប៉ះពាល់ធ្ងន់ធ្ងរ និងជ្រាលជ្រៅជាងមហាវិបត្តិទសវត្សរ៍ ១៩៣០ ទៅទៀត ។ វិបត្តិនេះ កើតចេញពីវិបត្តិទ្រព្យអ៊ីប៉ូតែកលេខ២ ហើយវាជះឥទ្ធិពលទៅលើទ្រព្យសកម្ម និងវិស័យផ្សេងៗទៀតនៃសេដ្ឋកិច្ច បង្កឱ្យមានការផ្តាច់ឥណទាន និងសាច់ប្រាក់ ការកាត់បន្ថយការងារ និងចំណូល និងការរលំរលាយអាជីវកម្ម និងទំនុកចិត្តរបស់អ្នកប្រើប្រាស់ ។

ទិន្នន័យក្នុងបទបង្ហាញនេះ បានបង្ហាញឡើងយ៉ាងច្បាស់ពីការថយចុះខ្លាំងនៃកំណើនសេដ្ឋកិច្ច ដោយសារវិបត្តិ ហើយគួបផ្សំនឹងទិន្នន័យនៅក្នុងព័ត៌មានថ្មីៗអំពីសេដ្ឋកិច្ចពិភពលោក ក្នុងខែមករា ឆ្នាំ២០០៩ របស់ IMF ការធ្លាក់ចុះសេដ្ឋកិច្ចក្នុងទូទាំងពិភពលោក គឺអាចមើលឃើញយ៉ាងច្បាស់ ។ កំណើនផលិតផលពិភពលោក បានធ្លាក់ចុះពី ៥,២% នៅឆ្នាំ២០០៧ មកត្រឹម ៣,៤% នៅឆ្នាំ២០០៨ ដោយសារការថយចុះកំណើន ផសស នៅក្នុងតំបន់ និងប្រទេសសំខាន់ៗទាំងអស់ ។ ក្នុងពេលជាមួយគ្នា កំណើនធាតុចេញនៅ

ក្រាហ្វិក ១: កំណើន ផសស ត្រីមាសទី៤ ឆ្នាំ២០០៨ (% នៃ SAAR)




*ប្រភព: ការវិភាគ Haver*

**SAAR: អត្រាប្រចាំឆ្នាំប្រែប្រួលតាមរដូវ*

សហរដ្ឋអាមេរិក ធ្លាក់ចុះជិត ១% តំបន់អឺរ៉ុបធ្លាក់ចុះ ១,៦% ជប៉ុនធ្លាក់ចុះ ២,៧% មកដល់ -0,៣% ខណៈពេលដែលចិនធ្លាក់ចុះ ៤% និងតំបន់អាស៊ាន-៥ ធ្លាក់ចុះ 0,៩% ។ ផសស របស់ប្រទេសជឿនលឿន និងប្រទេសឧស្សាហកម្មថ្មីៗ (NIEs) នៅត្រីមាសទី៤ ឆ្នាំ២០០៨ សុទ្ធតែបានរួមចុះទាំងអស់ (សូមមើលក្រាហ្វិក ១) ។

ផលិតកម្មឧស្សាហកម្ម និងការនាំចេញ ក៏ធ្លាក់ចុះយ៉ាងគំហុកដែរនៅឆ្នាំ២០០៨(ក្រាហ្វិក២) ។មិនតែប៉ុណ្ណោះ កំរិតទំនុកចិត្តរបស់បណ្តាអាជីវកម្ម និងអ្នកប្រើប្រាស់ ក៏ធ្លាក់ចុះដល់កំរិតទាបជាប្រវត្តិសាស្ត្រ ដែលបង្កការព្រួយបារម្ភយ៉ាងខ្លាំងពីសភាពការណ៍ដែលនឹងខិតមកដល់ ។

ក្រាហ្វិក ២: ផលិតកម្មឧស្សាហកម្ម និងការនាំចេញទំនិញ ក្នុងពិភពលោក (បំរែបំរួលជា % ក្នុង ៣ខែ នៃមធ្យមភាគបីខែរំកិល គិតជាប្រចាំឆ្នាំ)




*ប្រភព: IMF, ទិន្នន័យ GDS*

## វិបត្តិ: ផលប៉ះពាល់នៅកម្ពុជា

ដោយសារប្រទេសកម្ពុជា មានពាក់ព័ន្ធតិចតួចណាស់នឹងប្រភេទផលិតផលកំចីលេខ២ដែលបង្កគ្រោះថ្នាក់ ដូច្នេះក៏មិនទទួលរងឥទ្ធិពលដោយផ្ទាល់ពីចលាចលហិរញ្ញវត្ថុទេ ប៉ុន្តែត្រូវវិបត្តិប៉ះពាល់បាន តាមរយៈឥទ្ធិពលរបស់វាទៅលើវិស័យជំរុញកំណើនសំខាន់ៗ ។ ការធ្លាក់ចុះកំណើនសេដ្ឋកិច្ចកម្ពុជាពីកំណើនជាមធ្យមយ៉ាងខ្ពស់ដល់ ១០% នៅប៉ុន្មានឆ្នាំថ្មីៗ មកត្រឹម ៦% (តួលេខប៉ាន់ស្មានរបស់ IMF) ក្នុងឆ្នាំ២០០៨ គឺបណ្តាលមកពីការធ្លាក់ចុះនៃឧស្សាហកម្មកាត់ដេរ ទេសចរណ៍ និងសំណង់ ។ ការនាំចេញសំលៀកបំពាក់របស់កម្ពុជា ងាយនឹងទទួលរងការប៉ះទង្គិចពីផ្នែកខាងក្រៅណាស់ ដោយសារវាពឹងផ្អែកយ៉ាងខ្លាំងទៅលើទីផ្សារសហរដ្ឋអាមេរិក ។ កន្លងមក ផ្នែកនេះតែងដើរតាមនិន្នាការនៃការលក់រាយនៅសហរដ្ឋអាមេរិក ដូច្នេះវាក៏ធ្លាក់ចុះនៅពេលការលក់រាយនោះចាប់ផ្តើមធ្លាក់ចុះយ៉ាងខ្លាំង នៅពាក់កណ្តាលឆ្នាំ២០០៨(ក្រាហ្វិក៣) ។កំណើនបរិមាណនាំចេញសំលៀកបំពាក់ពីមួយឆ្នាំទៅមួយឆ្នាំ បានធ្លាក់ចុះជិតដល់ 0% នៅខែមករា ២០០៩ ។ វិស័យទេសចរណ៍ក៏ធ្លាក់ចុះស្រដៀងគ្នាដែរ ដោយកំណើនជាមធ្យមពីមួយឆ្នាំទៅមួយឆ្នាំធ្លាក់ចុះពី ២៥% មកត្រឹមប្រហែល ៩% នៅឆ្នាំ២០០៨ ។ ដោយសារប្រទេសរបស់ពួកគេទទួលរងការប៉ះពាល់ពីវិបត្តិ ភ្ញៀវទេសចរមកដល់កម្ពុជាក៏បានថយចុះចំនួន ហើយបានប៉ះពាល់ដល់ចំណូលលក់សំបុត្រចូលទស្សនាប្រាសាទអង្គរវត្ត (ក្រាហ្វិក ៤) ចំណូលពីការចាយវាយរបស់ទេសចរ ចំណូលពន្ធ និងការចិញ្ចឹមជីវិតរបស់ប្រជាជន ។ អតិផរណាខ្ពស់នៅឆ្នាំ២០០៨ និងការឡើងថ្លៃប្រាក់រៀល បានធ្វើឱ្យប្រទេសកម្ពុជាក្លាយជាគោលដៅទេសចរណ៍មានថ្លៃខ្ពស់ ធៀបនឹងប្រទេសដទៃទៀត ។

---

* លោក John Nelmes ជាតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំប្រទេសកម្ពុជា ។

ក្រាហ្វិក ៣: ការនាំចេញផលិតផលកាត់ដេរកម្ពុជា និងការលក់រាយនៅសហរដ្ឋអាមេរិក (កំណើនពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




សរុប មានកំណើនត្រឹមតែ ១% ប៉ុណ្ណោះ នៅចុងឆ្នាំ២០០៨ ហើយក៏ដាក់សំពាធទៅលើប្រព័ន្ធធនាគារក្នុងស្រុក ។ ការធ្លាក់ចុះវិស័យអចលនទ្រព្យ បានបង្កើនការព្រួយបារម្ភរបស់ប្រព័ន្ធធនាគារ ហើយក៏ជំរុញឱ្យមានការដាក់កំហិតលើកំចីធនាគារ ចំពោះវិស័យអចលនទ្រព្យនេះ ។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃឥណទានដល់វិស័យឯកជន បានធ្លាក់ចុះមកត្រឹម ៤៥% នៅខែមករា ២០០៩ ធៀបនឹងកំណើន ១០០% នៅខែឧសភា ២០០៨ ។

លទ្ធផលវិជ្ជមាននៃវិស័យកសិកម្មនៅឆ្នាំ២០០៨ បានជួយទ្រទ្រង់ដល់សេដ្ឋកិច្ចកម្ពុជា ។ ជាទូទៅ វិស័យកសិកម្ម បានបង្ហាញពីភាពធន់ទ្រាំល្អនឹងវិបត្តិ ទោះបីជាដំណាំសំរាប់នាំចេញសំខាន់ៗមួយចំនួន រងការប៉ះទង្គិចធ្ងន់ធ្ងរពីវិបត្តិក៏ដោយ ។ វិបត្តិសាកលបានជួយមួយកំរិតដល់អ្នកប្រើប្រាស់ ដោយវាបានបញ្ឈប់ការឡើងថ្លៃទំនិញផ្សេងៗ ដែលផុសចេញពីការឡើងថ្លៃម្ហូបអាហារ និងថាមពល តាំងពីឆ្នាំ២០០៦ មក ។ ប៉ុន្តែការធ្លាក់ថ្លៃផលិតផលបានកាត់បន្ថយប្រាក់ចំណេញរបស់ផលិតករ និងអ្នកនាំចេញ ហើយការថយចុះតំរូវការលើពិភពលោក បានធ្វើឱ្យពួកគេនៅសល់ផលិតផលក្នុងដៃ ព្រោះមិនមានអ្នកត្រូវការ ។ ទោះយ៉ាងនេះក្តី ថ្លៃផលិតផលនៅកម្ពុជា នៅតែមានកំរិតខ្ពស់ជាងកំរិតមធ្យមកាលពីមុនដដែល ហើយគួបផ្សំនឹងការឡើងថ្លៃប្រាក់រៀល កំលាំងប្រកួតប្រជែងរបស់កម្ពុជាត្រូវស្ថិតក្រោមសំពាធមួយ ។

ក្រាហ្វិក ៤: កម្ពុជា : ចំនួនទេសចរមកដល់សរុប និងប្រាក់ចំណូលពីអង្គរវត្ត ឆ្នាំ២០០៦_០៨ (កំណើនពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




*១ ចំណូលបានពីការលក់សំបុត្រ ។ ប្រភព: ទិន្នន័យផ្តល់ដោយអាជ្ញាធរកម្ពុជា និង ការប៉ាន់ស្មានរបស់បុគ្គលិក IMF*

វិស័យជំរុញកំណើនមួយទៀត គឺ វិស័យសំណង់ ក៏មានដំណើរការមិនសូវល្អដែរ នៅចំពោះមុខវិបត្តិនេះ ។ កត្តាសំខាន់នៃភាពស្ងប់ទ្រឹងក្នុងវិស័យសំណង់គឺ ការកាត់បន្ថយវិនិយោគដោយផ្ទាល់ពីបរទេស (FDI) ដោយសារការរឹតបន្តឹងលក្ខខណ្ឌផ្តល់ហិរញ្ញប្បទាន និងកំណើនការភ័យខ្លាចគ្រោះថ្នាក់ ។ សកម្មភាពសាងសង់នៅកម្ពុជា ជាប់ពាក់ព័ន្ធជិតស្និទ្ធនឹងការវិវត្តខាងអចលនទ្រព្យ ។ ការថយចុះលំហូរចូលវិនិយោគពីបរទេស រួមនឹងការរលំរលាយផ្នែកអចលនទ្រព្យក្នុងស្រុក បានប៉ះទង្គិចយ៉ាងខ្លាំងលើវិស័យសាងសង់ដែលមានកំណើនលឿនៗ កាលពីមួយឆ្នាំមុននេះ ។ លំហូរចូលវិនិយោគផ្ទាល់ពីបរទេស បានធ្លាក់ចុះរហូត នៅត្រីមាសទី៣ និង ទី៤ ឆ្នាំ២០០៨។

ស្ថានភាពសាច់ប្រាក់នៅក្នុងស្រុក ក៏តានតឹងឡើង ស្របគ្នានឹងនិន្នាការខាងលើដែរ ។ រូបិយវត្ថុទូទៅ ស្ទើរតែគ្មានកំណើនសោះ នៅខែមករា ២០០៩ ។ បញ្ញើជារូបិយវត្ថុបរទេស ដែលជាមធ្យមមានចំណែក ៩០% នៅក្នុងបញ្ញើ

## វិបត្តិ: ចក្ខុវិស័យ និងគោលនយោបាយ

ក្នុងពេលចំពោះមុខនេះ គេមិនទាន់មើលឃើញពីចុងបញ្ចប់នៃការធ្លាក់ចុះសេដ្ឋកិច្ចនៅឡើយទេ ។ ការទស្សន៍ទាយសំរាប់ឆ្នាំ២០០៩ នៅតែអាប់អួរដែលបង្ហាញពីកំណើនគំនិតទុទិដ្ឋិនិយមចំពោះស្ថានភាពសេដ្ឋកិច្ចសាកល ។ កន្លងមក គេបានប៉ាន់ស្មានថា ផលិតផលរបស់ពិភពលោក នឹងមានកំណើន ២,២% ប៉ុន្តែឥឡូវនេះ IMF ព្យាករណ៍ថា នឹងមានកំណើនតែ ០,៥% ប៉ុណ្ណោះ ។ ស្រដៀងគ្នាដែរ ចក្ខុវិស័យជាទូទៅសំរាប់កម្ពុជា មានភាពអាប់អួរជាងមុន ហើយ IMF បានកែតំរូវបញ្ចុះតួលេខប៉ាន់ស្មាន កំណើន ផសស ពិត របស់

ក្រាហ្វិក ៥: កំណើន ផសស ពិតនៅកម្ពុជា (បំរែបំរួលពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




កម្ពុជាសំរាប់ឆ្នាំ២០០៩ ពី ៤,៨% មកត្រឹម -០,៥% (ក្រាហ្វិក ៥) ។ ការរួមចុះខ្លាំងនេះ បណ្តាលមកពីភាពរាំរ៉ៃ និងកាន់តែធ្ងន់ធ្ងរ នៃការធ្លាក់ចុះខាងកាត់ដេរ ទេសចរណ៍ និងសំណង់ ។ លោក Nelmes បានរំលឹកថា តាមការព្យាករណ៍ ការលក់រាយរបស់សហរដ្ឋអាមេរិកត្រូវធ្លាក់ចុះអស់ ១០% នៅឆ្នាំនេះ ដូច្នេះការនាំចេញផលិតផលកាត់ដេរកម្ពុជា ប្រាកដជាត្រូវរងគ្រោះ ។ ទន្ទឹមគ្នានេះ កំណើនវិស័យទេសចរណ៍ឆ្នាំ២០០៩ នៅកម្ពុជា នឹងធ្លាក់ចុះរហូតដល់ -០,៥% ។ ផ្ទុយទៅវិញ វិស័យកសិកម្មរំពឹងថានឹងបន្តដំណើរការវិជ្ជមានពីឆ្នាំមុនទៀត បើទោះជាសំពាធបរិត្តផរណាដែលកំពុងតែកើតមានមិនសូវអំណោយផលដល់វិស័យនេះក្តី ។ នៅឆ្នាំ២០១០ សេដ្ឋកិច្ចប្រហែលរើបឡើងវិញយឺតៗ ប៉ុន្តែការធ្លាក់ចុះក៏នៅតែអាចកើតមានទៀត ។

ជាការពិតណាស់ ផ្លូវសំរាប់ការរើបសេដ្ឋកិច្ចឡើងវិញ វាមានការលំបាកច្រើន ។ ក្នុងនេះគួរអនុវត្តយុទ្ធសាស្ត្រ បន្ធូរបន្ថយបន្ទុកពន្ធមួយ ដើម្បីជួយសង្គ្រោះដល់វិស័យ និងប្រជាជននានាដែលរងគ្រោះដោយវិបត្តិ ។ ឆ្នាំនេះ ថវិកាជាតិរំពឹងថានឹងមានឱនភាពដល់ ៤,៧៥% នៃ ផសស ។ ដើម្បីឱ្យគោលនយោបាយបង្កើនចំណាយថវិកានេះ អាចសំរេចគោលដៅបាន ត្រូវផ្តល់អាទិភាពទៅលើចំនាយសំរាប់ប្រព័ន្ធសុវត្ថិភាពសង្គម និងហេដ្ឋារចនាសម្ព័ន្ធ ។ ម្យ៉ាងទៀតក៏មិនគួរបោះបង់ចោលនូវជោគជ័យដែលទទួលបានដោយលំបាកក្នុងប៉ុន្មានឆ្នាំកន្លងមក ក្នុងការគ្រប់គ្រងចំណូលនោះទេ ។

គោលនយោបាយផ្សេងទៀតសំរាប់ដោះស្រាយ រួមមាន ការបង្កើនសាច់ប្រាក់ (ប៉ុន្តែមធ្យោបាយនេះគឺមានកំរិត) និងការបង្កើតឧបករណ៍រូបិយវត្ថុដែលអាចជួយសំរួលដល់ប្រតិបត្តិការអន្តរធនាគារ ។ សកម្មភាពនាពេលថ្មីៗ ដើម្បីពង្រឹងការគ្រប់គ្រងធនាគារពីចម្ងាយ និងដល់កន្លែង បានផ្តល់លទ្ធផលគួរឱ្យពេញចិត្ត ហើយត្រូវបន្តអនុវត្ត និងកែលំអថែមទៀត ។ ឱសថសំខាន់បំផុតសំរាប់ព្យាបាល ឬបង្ការវិបត្តិបច្ចុប្បន្ន និងវិបត្តិនាពេលអនាគតនោះ គឺការដោះស្រាយនូវឧបសគ្គខាងរចនាសម្ព័ន្ធ ដែលកំពុងរារាំងដល់កំណើនសេដ្ឋកិច្ចមានមូលដ្ឋានធំទូលាយ និងការពង្រីកសមត្ថភាពប្រកួតប្រជែង ៕

***តើអ្នកដឹងទេថា ...?***

... ជាលទ្ធផលនៃវិបត្តិ សហរដ្ឋអាមេរិក តំបន់អឺរ៉ូ និងជប៉ុន បានធ្លាក់ចុះសេដ្ឋកិច្ចព្រមៗគ្នា ជាលើកដំបូង គិតតាំងពីសង្គ្រាមលោកលើកទី២ មក? សេដ្ឋកិច្ចសហរដ្ឋអាមេរិក តំបន់អឺរ៉ូ និងជប៉ុន បានរួមចុះជាផ្លូវការ នៅចុងឆ្នាំ២០០៨ ។ តាមធម្មតាគេតែងចាត់ទុកថា មានការរួមចុះសេដ្ឋកិច្ច បើសិនមានកំណើនអវិជ្ជមាននៃ ផសស យ៉ាងតិចបំផុតចំនួន ២ ត្រីមាសបន្តបន្ទាប់ ។

*ប្រភព: **CNN (2008), J. Menon** នៅក្នុងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ ២០០៨-២០០៩*

... ជាលទ្ធផលនៃវិបត្តិ សេដ្ឋកិច្ចប្រទេសអៀស្លង់ បានដួលរលំ ហើយប្រទេសជាច្រើនទៀតក៏កំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់បែបនេះដែរ? តាំងពីពាក់កណ្តាលឆ្នាំ២០០៨ ធនាគារសំខាន់ៗទាំងបីរបស់ប្រទេសអៀស្លង់ បានដួលរលំ ហើយរូបិយវត្ថុរបស់អៀស្លង់ បានធ្លាក់ថ្លៃយ៉ាងលឿន រហូតដល់ស្ទើងអស់តំលៃរលីង ។ គេបានវាយស្មានថា ប្រទេសមួយចំនួន ដូចជា ស្វីស និងចក្រភពអង់គ្លេសជាដើម អាចមានលទ្ធផលដូចប្រទេសអៀស្លង់ដែរ ។ ទោះបីមានការជជែកដេញដោលជាច្រើនថាប្រទេសមួយអាចក្ស័យធនបានពិតមែនឬយ៉ាងណាក្តី ប៉ុន្តែស្ថានភាពក្ស័យធនរបស់ប្រទេសតាមធម្មតាតែងមានន័យថា ប្រទេសនោះលែងអាចសងបំណុលក្រៅប្រទេសរបស់ខ្លួនបាន ។

*ប្រភព: ទស្សនាវដ្តី Economist (2008), សារព័ត៌មាន Market Oracle (2009)*